**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣០៣៨ ព.ណ.ន.ន...

ថ្ងៃសុក្រ ៤កើត ខែកត្តិក ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង

ព្រះរាជាណាចក្រកម្ពុជាបានបញ្ចប់នីតិវិធីផ្ទៃក្នុង និងផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដោយព្រះរាជក្រមលេខ នស/រកម/០១២២/០០១ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ និងយោងតាមសេចក្តីជូនដំណឹងរបស់ស្ថានទូតសាធារណរដ្ឋកូរ៉េនៅភ្នំពេញស្តីពីភាគីសាធារណរដ្ឋកូរ៉េបានបំពេញនីតិវិធីផ្ទៃក្នុងចប់សព្វគ្រប់។ នាយកដ្ឋាននាំចេញ-នាំចូល នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ និងអ្នកនាំចេញទាំងអស់ឱ្យ បានជ្រាបថា៖ ក្រសួងពាណិជ្ជកម្មនឹងដាក់ឱ្យអនុវត្តការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ទម្រង់ស៊ីខេ(Form CK) តាមប្រព័ន្ធស្វ័យប្រវត្តកម្មតាមរយៈគេហទំព័រ https://co.moc.gov.kh ក្នុងការស្នើសុំនាំចេញទំនិញទៅកាន់ទីផ្សារនៃសាធារណរដ្ឋកូរ៉េចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ នេះតទៅ។

ចំពោះព័ត៌មានលម្អិតខាងលើ សូមទំនាក់ទំនងមន្ត្រី នៃនាយកដ្ឋាននាំចេញ នាំចូល៖

១-ឯកឧត្តម អ៊ុន ចាន់ថា ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធាននាយកដ្ឋាននាំចេញ-នាំចូល
ទូរស័ព្ទលេខ: ០១២ ៨៣៣ ៣៩៧ សារអេឡិចត្រូនិច: unchantha2017@gmail.com

២-លោក ស៊ី បាទិត្យ អនុប្រធាននាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម
ទូរស័ព្ទលេខ: ០១២ ៩៤៨ ៤៨៤ សារអេឡិចត្រូនិច: batithsy@yahoo.com

៣-លោក ស្វាយ សុផល ប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ-នាំចូល
ទូរស័ព្ទលេខ: ០១១ ៧៥៧ ១៦៥ សារអេឡិចត្រូនិច: sophal.svay@yahoo.com

៤-លោក សុខ វណ្ណថុល អនុប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ-នាំចូល
ទូរស័ព្ទលេខ: ០១២ ៥៩៥ ៦១៦ សារអេឡិចត្រូនិច: vanthol@gmail.com

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ជាផលិតករ និងអ្នកនាំចេញទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

**សូមអរគុណ**

## Annex 3-D
## Certificate of Origin

### ORIGINAL (DUPLICATE/TRIPLICATE)

1. Exporter's name and address:

2. Producer's name and address, if known

3. Importer's or Consignee's name and address

Certificate of Origin No.

CAMBODIA-KOREA FREE TRADE AGREEMENT

CERTIFICATE OF ORIGIN

(Combined Declaration and Certificate)

FORM CK

Issued in ......................................

(Country)

See Overleaf Notes

4. Means of transport and route (as far as known)

Departure date

Vessel's name/Aircraft etc.

Port of Discharge

5. For Official Use

☐ Preferential Tariff Treatment Given Under Cambodia-Korea Free Trade Agreement

☐ Preferential Tariff Treatment Not Given (Please state reason/s)

..............................................................................

Signature of Authorized Signatory of the Importing country

| 6. Item number | 7. Marks and numbers on packages | 8. Number and type of packages, description of goods (including quantity where appropriate and HS number of the importing country) | 9. Origin criterion (see Overleaf Notes ) | 10. Gross weight or other quantity and Value (FOB only when RVC criterion is used) | 11. Number and date of Invoices |
|---|---|---|---|---|---|
| | | | | | |

12. Declaration by the exporter

The undersigned hereby declares that the above details and statement are correct; that all the goods were produced in

..............................................................

(Country)

and that they comply with the origin requirements specified for these goods in the Cambodia-Korea Free Trade Agreement for the goods exported to

..............................................................

(Importing Country)

..............................................................

Place and date, signature of authorized signatory

13. Certification

It is hereby certified, on the basis of control carried out, that the declaration by the exporter is correct.

..............................................................................

Place and date, signature and stamp of certifying authority

14. ☐ Third Party Invoicing

OVERLEAF NOTES

1. The Parties which accept this form for purpose of preferential tariff under the Cambodia-Korea Free Trade Agreement (CKFTA) are KINGDOM OF CAMBODIA and REPUBLIC OF KOREA.

2. CONDITIONS: To enjoy preferential tariff under the CKFTA, goods sent to any Parties listed above:

(i) must fall within a description of goods eligible for concessions in the country of destination;

(ii) must comply with the consignment conditions in accordance with Article 3.9 of Chapter Three (Rules of Origin) of the CKFTA; and

(iii) must comply with the origin criteria in Chapter Three (Rules of Origin) of the CKFTA.

3. ORIGIN CRITERIA: For goods that meet the origin criteria, the exporter or producer must indicate in box 9 of this Form, the origin criteria met, in the manner shown in the following table:

| Circumstances of production or manufacture in the first country named in box 12 of this form | Insert in box 9 |
|---|---|
| (a) Goods which are wholly obtained or produced in the territory of the exporting Party as set out and defined in Article 3.3 of this Chapter | "WO" |
| (b) Goods which are produced in the territory of the exporting Party exclusively from originating materials | "PE" |
| (c) Goods satisfying the Product Specific Rules<br>- Change in Tariff Classification<br>- Regional Value Content<br>- Change in Tariff Classification + Regional Value Content<br>- Specific Processes | - "CTC"<br>- "RVC" that needs to be met for the good to qualify as originating; e.g. "RVC 45%"<br>- The combination rule that needs to be met for good to qualify as originating; e.g. "CTH + RVC 40%"<br>- "Specific Processes" |
| (d) Goods satisfying Article 3.5 of Chapter Three (Rules of Origin) | "Article 3.5" |

4. EACH ARTICLE MUST QUALIFY: It should be noted that all the goods in a consignment must qualify separately in their own right. This is of particular relevance when similar articles of different sizes or spare parts are sent.

5. DESCRIPTION OF GOODS: The description of goods must be sufficiently detailed to enable the goods to be identified by the Customs Officers examining them. Any trade mark shall also be specified.

6. FREE-ON-BOARD (FOB) VALUE: The FOB value in box 10 shall be reflected only when the Regional Value Content criterion is applied in determining the origin of goods.

7. HARMONIZED SYSTEM NUMBER: The Harmonized System number (six-digit level) shall be that of the importing Party.

8. EXPORTER: The term "Exporter" in box 12 may include the manufacturer or the producer.

9. FOR OFFICIAL USE: The Customs Administration of the importing Party must indicate (√) in the relevant boxes in box 5 whether or not preferential tariff is accorded.

10. THIRD PARTY INVOICING: In cases where invoices are issued by a third party, the "Third Party Invoicing" box should be ticked (√) and such information as the name and country of the company issuing the invoice shall be indicated in box 14.

EMBASSY OF THE REPUBLIC OF KOREA

KCA-2022-466

The Embassy of the Republic of Korea in Phnom Penh presents its compliments to the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia and has the honour to refer to the Ministry's Note No.233 MFA-IC/LC1 dated 9 February 2022 notifying the completion of the internal procedures of the Cambodian side for the entry into force of the *Free Trade Agreement between the Government of the Republic of Korea and the Government of the Kingdom of Cambodia*, which was signed at Seoul and Phnom Penh on 26 October 2021 (hereinafter referred to as the "Agreement").

The Embassy has further the honour to notify the Ministry that the Government of the Republic of Korea has completed its domestic procedures for the entry into force of the Agreement and, therefore, the Agreement shall enter into force on 1 December 2022, which is the sixty days after this Note dated 2 October 2022, in accordance with Article 10.10 of the Agreement.

The Embassy of the Republic of Korea avails itself of this opportunity to renew to the Ministry of Foreign Affairs and International Cooperation of the Kingdom of Cambodia the assurances of its highest consideration.

Phnom Penh, 2 October 2022

# ព្រះរាជក្រម

## យើង

នស/រកម/០១២២/០០៦

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ០៧៣
ថ្ងៃ: ...ទី ២ ខែកុម្ភៈ ឆ្នាំ២០២២
ម៉ោង: ១១:០០ ព្រឹក

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
## រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
## និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ

**មាត្រា១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ១៤កោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២២

ពរស.២២០១.០៥៧

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**